# បុណ្យចូលឆ្នាំខ្មែរ

✡✡✡✡✡✡✡

មនុស្សគ្រប់ជាតិសាសន៍ តែងប្រារព្ធពិធីចូលឆ្នាំថ្មីដែលជាប្រពៃណីរបស់ប្រជាជាតិរៀងៗខ្លួន។ គ្រាន់តែគេនិយមកំណត់ពេលវេលានៃ ការរៀបចំបុណ្យនេះប្លែកៗគ្នាស្របទៅតាមជំនឿទំនៀមទម្លាប់និងប្រពៃណី របស់គេប៉ុណ្ណោះ។ ជនជាតិខ្មែរយើង ក៏មានប្រវត្តិធ្វើបុណ្យចូលឆ្នាំតាំងពីបុរាណកាលជារៀងរាល់ឆ្នាំ រហូតមក យើងបានប្រទះឃើញឯកសារជាច្រើន ដែលនិយាយពីពិធីបុណ្យចូលឆ្នាំនិងឧស្សាហ៍ បានស្តាប់ការនិទានរឿងរបស់ចាស់ទុំជាច្រើន។

## ប្រវត្តិ

មានតំណាលថា នៅដើមនៃភទ្ទកប្ប មានសេដ្ឋីម្នាក់មានបុត្រម្នាក់ឈ្មោះធម្មបាលកុមារ ជាអ្នកមានចំណេះវិជ្ជាដ៏វិសេស រៀនចេះចប់ត្រៃវេទតាំងពីអាយុបាន៧ឆ្នាំ។ សេដ្ឋីបិតាបានសាងប្រាសាទឲ្យនៅទៀបដើមជ្រៃមួយធំនៅឆ្នេរទន្លេដែលជាទីនៅនៃបក្សីទាំងឡាយ ធម្មបាលកុមារនោះ បានចេះទាំងភាសាបក្សីទាំងពួងផង ហើយបានជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួងផង។ គ្រានោះមនុស្សលោករមែងរាប់អានព្រះមហាព្រហ្មនិង កុបិលមហាព្រហ្មមួយអង្គទៀតដែលជាអ្នក សម្តែងមង្គលដល់មនុស្សទាំងពួង។ ពេលនោះកុបិលមហាព្រហ្ម បានជ្រាបពត៌មានក៏ចុះមកសួរបញ្ហានឹងធម្មបាលកុមារ ៣ "ខ" ដោយសន្យាទុកថា បើដោះប្រស្នាបាននឹងកាត់ក្បាលបូជាធម្មបាលកុមារ តែបើដោះមិនរួចនឹងកាត់ក្បាលធម្មបាលកុមារវិញ។ ធម្មបាលកុមារសុំឲ្យពន្យារពេលចំនួន៧ថ្ងៃសិនដើម្បីគិតប្រស្នា។ លុះកន្លងទៅ៦ថ្ងៃហើយក៏នៅតែគិតមិនឃើញដឹងខ្លួនថាព្រឹកនេះនឹងត្រូវស្លាប់ដោយអាជ្ញាកុបិលមហាព្រហ្មជាប្រាកដហើយ។ ដូច្នេះ គួរតែរត់ទៅលាក់ខ្លួនពួនអាត្មាឲ្យស្លាប់ដោយខ្លួនឯងប្រសើរជាង ទើបចុះពីប្រាសាទទៅដេកពួននៅក្រោមដើមត្នោតមួយគូ ដើមត្នោតនោះមានសត្វឥន្ទ្រីញីឈ្មោលធ្វើសំបុកអាស្រ័យនៅ វេលាយប់ឥន្ទ្រីញីសួរឥន្ទ្រីឈ្មោលថា ព្រឹកនេះយើងបានអាហារពីណាស៊ី? ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងស៊ីសាច់ធម្មបាលកុមារដែលត្រូវកុបិលមហាព្រហ្មសម្លាប់ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រី

ញីសួរថា **ប្រស្នានោះដូចម្តេច?** ឥន្ទ្រីឈ្មោលឆ្លើយថា: **វេលាព្រឹកសិរីសួស្តីស្ថិតនៅទីណា?** ត្រូវឆ្លើយថា នៅមុខ ហេតុនេះទើបមនុស្សទាំងឡាយត្រូវយកទឹកលប់មុខ ខមួយទៀតថា **ថ្ងៃត្រង់សិរីស្ថិតនៅត្រង់ណា?** ត្រូវឆ្លើយថា នៅទ្រូងហេតុនោះទើបមនុស្សត្រូវយកទឹកលាងទ្រូង ខមួយទៀតថា **វេលាល្ងាចសិរីស្ថិតនៅទីណា?** ត្រូវឆ្លើយថា នៅជើងហេតុនេះ ទើប មនុស្ស ទាំងឡាយត្រូវយកទឹកលាងជើង។ ធម្មបាលកុមារបានលឺដូច្នេះ ក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើងកុបិលមហាព្រហ្មក៏មកសួរប្រស្នា ធម្មបាលកុមារឆ្លើយដោះស្រាយតាមដែលបានឮមក កបិលមហាព្រហ្មហៅទេពធីតាទាំង ៧នាក់ដែលជា បាទបរិចារិកាព្រះឥន្ទ្រ មកប្រាប់ថា ឥឡូវបិតាត្រូវកាត់ក្បាលបូជាធម្មបាលកុមារ តែបើដាក់ក្បាលនោះលើផែនដី ក៏នឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាសភ្លៀងក៏រាំងបើចោល ក្នុងមហាសមុទ្រទឹកក៏រីងស្ងួតហួតអស់ ដូច្នេះសូមឲ្យកូនទាំង ៧នាក់យកពានមកទទួលក្បាល ថាហើយក៏កាត់ក្បាលហុចទៅឲ្យនាងទុង្សា ជាកូនច្បង នាងទុង្សាទើបយកពានទៅទទួលក្បាលបិតាហើយហែប្រទក្សិណភ្នំព្រះសុមេរុ ៦០នាទីហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុងមណ្ឌលនៅក្នុងគុហាគន្ធមាលី ភ្នំកៃលាស បូជាគ្រឿងទិព្វផ្សេងៗ ព្រះវិស្សកម្មទេវបុត្រក៏និមិត្តរោងទិព្វដ៏ហើយដោយកែវ៧ប្រការ ឈ្មោះថា "ភគវតីសភា" ឲ្យជាទីប្រជុំនៃទេវតាលុះដល់គម្រប់១ឆ្នាំជាសង្រ្កាន្ត នាងទេពធីតាទាំង៧ក៏ផ្លាស់វេនគ្នា មកអញ្ជើញក្បាលកបិលមហាព្រហ្ម ចេញមកហែប្រទក្សិណ ភ្នំព្រះសុមេរុរាល់ៗឆ្នាំហើយត្រឡប់ទៅស្ថានទេវលោកវិញ។

## ឈ្មោះទេពធីតាមហាសង្ក្រាន្ត និង គ្រឿងអាភរណៈ

*ថ្ងៃ ទេពធីតាមហាសង្រ្កាន គ្រឿងអាភរណៈ*

***ថ្ងៃអាទិត្យ*** *ទុង្សាទេវី សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ អាវុធស្តាំកងចក្រ ឆ្វេងសង្ខ័ពាហានៈគ្រុឌ ។*

***ថ្ងៃចន្ទ័*** *គោរាគទេវី សៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់មុក្តា ភក្សាហារប្រេង អាវុធស្តាំព្រះខ័ន អាវុធឆ្វេងឈើច្រត់ ពាហនៈ ខ្លា ។*

***ថ្ងៃអង្គារ*** *រាក្សសាទេវី សៀតផ្កាឈូក គ្រឿងប្រដាប់មោរ៉ា ភក្សាហារលោហិត អាវុធស្តាំ ត្រីសូល៍*

*អាវុធធ្នូធ្នូ ពាហនៈអស្សតរ ។*

***ថ្ងៃពុធ*** *មណ្ឌាទេវី សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសប្បិ អាវុធស្ពាំម្ខុល អាវុធធ្នូឈើច្រត់ ពាហនៈ លា។*

***ថ្ងៃព្រហស្បតិ៍*** *កិរិណីទេវី សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក លូ អាវុធស្ពាំកង្វេរ អាវុធធ្នូកាំភ្លើង ពាហនៈដំរី ។*

***ថ្ងៃសុក្រ*** *កិមិរាទេវី សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្សរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្ពាំព្រះខ័ន ធ្នូពិណាពាហនៈក្របី ។*

***ថ្ងៃសៅរ៍*** *មហោទរា សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរត័ន៍ ភក្សាហារសាច់ទ្រាយ អាវុធស្ពាំកងចក្រ ធ្នូត្រីសូល៍ ពាហនៈក្ងោក ។*

# ទំនៀមចូលឆ្នាំ

*កាលដើមឡើយខ្មែរយើងប្រារព្ធធ្វើបុណ្យចូលឆ្នាំក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះជាខែដើមឆ្នាំ។ នាសម័យព្រេងនាយ ឆ្នាំនីមួយៗចែកជា៣រដូវតាមចន្ទគតិ គឺ**ហេមន្តរដូវ គិម្ហរដូវ និង វស្សានរដូវ** ។ បុរាណាចារ្យលោកគិតថា **ហេមន្តរដូវ**ជារដូវត្រជាក់ ចាត់ទុកជារដូវដើមឆ្នាំ ប្រៀបបាននឹងពេលព្រឹកដែលផុតពីរាត្រីគឺ ជាដើមថ្ងៃ ។ **គិម្ហរដូវ** ជារដូវក្តៅ ចាត់ទុកជាកណ្តាលឆ្នាំ ប្រៀបដូចជាពេលថ្ងៃត្រង់ ។ **វស្សានរដូវ** ជារដូវដែលមេឃមីរងងឹត មានភ្លៀងផ្គរ ត្រូវចាត់ទុកជាចុងឆ្នាំ ប្រៀបបាននឹងពេលព្រលប់ ។*

*ទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន ៣ថ្ងៃ។ **ថ្ងៃដំបូងជាថ្ងៃមហាសង្ក្រាន្ត ថ្ងៃទី២ ជាថ្ងៃវ័នបត ថ្ងៃទី៣ ជាថ្ងៃឡើងស័ក**។ ឯការកំណត់ខែ ថ្ងៃ ម៉ោង នាទីដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេព្តាឆ្នាំថ្មីត្រូវចុះមកទទួលតំណែងពីទេព្តាឆ្នាំចាស់នោះ គេអាចដឹងបានយ៉ាងទៀងទាត់ ដោយអាស្រ័យតាមក្បួនហោរាសាស្ត្របែបបុរាណគឺក្បួនមហាសង្ក្រាន្ត នេះឯង។*

*តើថ្ងៃចូលឆ្នាំថ្មីរបស់ខ្មែរយើងត្រូវលើខែណា ? ថ្ងៃណា ? ចាប់ពីត្រឹមសម័យក្រុងនគរធំឡើងទៅ ខ្មែរយើងប្រើចន្ទគតិ (ដំណើរព្រះច័ន្ទ) ទើបកំណត់យកខែមិគសិរជាខែចូលឆ្នាំ ហើយជាខែទី១*

ខែកត្តិកជាខែទី១២ ។ លុះក្រោយមកទើបគេនិយមប្រើសុរិយគតិ (ដំណើរព្រះអាទិត្យ)ជាសំខាន់វិញ ហើយកំណត់ចូលឆ្នាំក្នុងខែចែត្រ (ខែទី៥) ដែលជាឆ្នាំកំនត់ព្រះអាទិត្យចូលកាន់មេសរាសី ហើយថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី១៣ នៃខែមេសា (ចេត្រ) រៀងរាល់ឆ្នាំ ប៉ុន្តែយូរៗទៅមានភ្ជាត់ម្តងៗ ចូលឆ្នាំក្នុងថ្ងៃទី១៤ ក៏មានខ្លះដែរ ។ ការផ្លាស់ប្តូរនេះព្រោះបុព្វបុរសយើងយល់ឃើញថា នៅខែមិគសិរនេះប្រជាកសិករខ្មែរយើង រវល់មមាញឹក្នុងរបរកសិកម្ម មានស្រែចំការជាដើមទើបលោកលើកកំណត់ពេលចូលឆ្នាំមកធ្វើនៅក្នុងខែចេត្រវិញ ដោយហេតុថាខែចេត្រកិច្ចការច្រូតកាត់បោកបែន បានចប់សព្វគ្រប់ ហើយប្រជាពលរដ្ឋខ្មែរយើងទំនេរ មានឱកាសធ្វើបុណ្យទានកំសាន្តសប្បាយតាមប្រាថ្នា ។ ការកំណត់នេះក៏ជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃ ។ មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមសុរិយគតិមានឈ្មោះថា «សាមញ្ញសង្ក្រាន្ត»(ព្រះអាទិត្យដើរ ត្រង់ពី លើក្បាលជាសង្ក្រាន្ត)។ មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមចន្ទគតិហៅថា «អាយន្តសង្ក្រាន្ត»(ពេលដែលព្រះអាទិត្យដើរបញ្ឆៀង មិនត្រង់ពីលើ) ។ គេនៅប្រើចន្ទគតិអែបគ្នានឹងសុរិយគតិដែរ ព្រោះចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធប្បញ្ញត្តិច្រើន ។ ចំណែកឯថ្ងៃចូលឆ្នាំតាមចន្ទគតិមិនបានទៀងទាត់ជាថ្ងៃណាមួយទេ ជួនកាលចូលឆ្នាំក្នុងវេលាខ្នើត ជួនកាលទៀតក្នុងវេលារនោចទៅវិញ ។ ប៉ុន្តែនៅក្នុងរវាង១ខែគឺមិនមុនថ្ងៃ ៤កើត ខែចេត្រ និងមិនហួសថ្ងៃ ៤កើតខែពិសាខទេ ដូចនេះសង្ក្រាន្តខ្លះធ្លាក់ទៅក្នុងខែពិសាខក៏មាន។

ចំពោះពិធីផ្សេងៗខ្មែរយើងមានរៀបចំតាមប្រពៃណីដូចតទៅ នៅពេលមុនចូលឆ្នាំគេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារសំអាតផ្ទះសំបែង រែកទឹកដាក់ពាង រកឧសទុកកាត់សំលៀកបំពាក់ថ្មីៗជាដើម ។ ថ្ងៃចូលឆ្នាំមកដល់គេរៀបគ្រឿងសក្ការៈបូជាសំរាប់ទទួលទេវតាថ្មីមានៈ បាយសីមួយគូ ស្លាធម៌១គូ ធូប៥ ទៀន៥ ទឹកអប់១គូ ផ្កាភ្ញី លាជ ទឹកមួយផ្តិល និងភេសជ្ជៈនំនែកផ្លែឈើគ្រប់មុខ។ ចំណែកផ្ទះសំបែងគេតុបតែងរំលេចដោយអំពូលអគ្គីសនីខ្សែតូចៗចំរុះពណ៌ ឬចង្កៀងគោមគ្រប់ពណ៌សំរាប់ទទួលទេព្តាថ្មី។ លុះដល់វេលាកំណត់ទេព្តាថ្មីចុះមកហើយ គេនាំកូនចៅអង្គុយជុំគ្នា នៅជិតកន្ទែងរៀបគ្រឿងសក្ការៈនោះ ហើយអុជទៀន ធូបបាញ់ទឹកអប់ បន់ស្រន់សុំសេចក្តីសុខចំរើនគ្រប់ប្រការពីទេព្តាថ្មី ។ ចំពោះគ្រឿងសក្ការៈ និងក្រយាស្ងោយដាក់ថ្វាយទេព្តានោះ គេនិយមតំរូវតាមចិត្តទេវតាដែលនឹងត្រូវចុះក្នុងឆ្នាំនីមួយៗ។ ឧទាហរណ៍ : បើ

*ទេវតាដែលត្រូវចុះមកនោះសោយលូ សណ្តែក គេដាក់សណ្តែក លូ ថ្វាយ ។ល។ ឯពិធី ៣ថ្ងៃនៃថ្ងៃចូលឆ្នាំនោះគឺ :*

- ***ថ្ងៃទី១*** *: គេយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត ។ ពេលល្ងាចគេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយនៅជុំវិញព្រះវិហារឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះ ។ នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ព្រះសង្ឃ និមន្តលោកចំរើនព្រះបរិត្ត និងសំដែងធម្មទេសនា ។*
- ***ថ្ងៃទី២*** *: កូនចៅជូនសំលៀកបំពាក់ នំចំណី លុយកាក់ដល់អ្នកមានគុណ មានឪពុកម្តាយ ជីដូនជីតាជាដើម ។ ជូនកាលគេធ្វើទានដល់មនុស្សបំរើ ឬអ្នកក្រីក្រទៀតផង ។ ពេលរសៀលគេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចជាចូឡាមណីចេតិយ ហើយនិមន្តព្រះសង្ឃបង្សុកូលចេតិយបញ្ជូនមគ្គផលដល់វិបាកវិញ្ញាណបងប្អូននិងញាតកាទាំង៧សន្តាន ដែលបានស្លាប់ទៅ ។*
- ***ថ្ងៃទី៣*** *: ពេលព្រឹកនិមន្តព្រះសង្ឃឆ្លងភ្នំខ្សាច់ ។ ពេលល្ងាចនិមន្តព្រះសង្ឃស្រង់ទឹកនិងស្រង់ព្រះពុទ្ធរូប ។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកំសាន្តសប្បាយជាច្រើន ដូចជាលេង បោះអង្គុញ់ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ចាប់កូនខ្លែងជាដើម និងមានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង និង សៀមរាប) ជាពិសេសទៀតគឺរាំវង់តែអាស្រ័យទៅតាមការនិយមចូលចិត្តរបស់មនុស្សម្នាក់ៗ គឺខ្លះនិយមនាំគ្នាដើរកំសាន្តបន្ត ខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាម។*

## ពិធីស្រង់ព្រះ

*-មហាសំការសូត្រដែលមានមកក្នុងគម្ពីរសុត្តជាតក ជាមគធភាសាបាននិទានថា ថ្ងៃសង្ក្រាន្តឆ្នាំថ្មីជិតចូលមកដល់ ព្រះបាទបសេនទិកោសលបានរៀបចំជាបារាំយ៉ាស្អាតនៅឆ្នេរស្ទឹងមួយ ហើយក៏និមន្តព្រះពុទ្ធនិងព្រះសង្ឃស្រង់ទឹក រួចសមាទានសីល ប្រគេនភត្តាហារចំពោះព្រះពុទ្ធព្រមទាំងភិក្ខុសង្ឃនៅទីនោះ ។ គម្ពីរនេះដដែលបានបញ្ជាក់ទៀតថា អ្នកដែលបានស្រង់ទឹកព្រះសង្ឃ*

*មាតបិតា គ្រូឧបជ្ឈាយ៍ មានអានិសង្សច្រើនណាស់ ។ អនាគតជាតិនឹងបានទៅកើតក្នុងទេវ-លោក បានជាស្តេចចក្រពត្តិ មានបុណ្យបារមីច្រើន មានរូបល្អ មានទ្រព្យសម្បត្តិច្រើន មានសេចក្តីសុខគ្រប់យ៉ាង-ល-។*

*-គម្ពីរបញ្ញាសជាតក ត្រង់ជាតកទី៣១ បានបញ្ជាក់អំពីអានិសង្សនៃការស្រង់ទឹកព្រះសង្ឃ ដូចមហាសំការសូត្រដែរ គ្រាន់តែខុសគ្នាត្រង់មិនបានបញ្ជាក់ថាក្នុងឱកាសចូលឆ្នាំនោះប៉ុណ្ណោះ ។ លោកលើឧទាហរណ៍ដូចជាព្រះបាទបុប្ផរាជដែលបាននិមន្តព្រះឧសភត្ថេរ ក្នុងសាសនាព្រះពុទ្ធសរណង្ករ អោយស្រង់ទឹក ។ លុះអនាគតជាតិទៅ បានទៅកើតក្នុងទេវលោក មានបុណ្យបារមីច្រើន ហើយទីបំផុតបានជាស្តេចចក្រពត្តិក្នុងជម្ពូទ្វីបនេះ ។*

*- ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ពេលចូលឆ្នាំម្តងៗ កេតែងធ្វើពិធីមួយ ដោយនិមន្តព្រះពុទ្ធរូបមានមហិទ្ធិឫទ្ធិ ២៥ ព្រះអង្គ ដែលជាតំណាងអាណាខេត្តទាំងឡាយក្នុងព្រះរាជាណាចក្រមកធ្វើពិធីស្រង់ព្រះនៅប្រាសាទជ័យស្រី (ប្រាសាទព្រះខ័ន) រួចគេដង្ហែព្រះពុទ្ធរូបទាំងនោះជាក្បួនយ៉ាងមហោឡារិក មុននឹងយកទៅតំកល់នៅកន្លែងដើមវិញ ។*

*ដោយមានជំនឿលើនិទាននិងទំនៀមរបស់ដូនតាយើង ដូចខាងលើនេះហើយបានជាមានទម្លាប់ជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃនេះ ។ តែដល់ពេលចូលឆ្នាំម្តងៗ គេតែធ្វើពិធីស្រង់ទឹកព្រះពុទ្ធរូប-ព្រះសង្ឃ-មាតាបិតា-ជីដូនជីតា បុព្វការី នៅតាមវត្តអារាមនិងតាមភូមិស្រុក ។*

# ពិធីពូនភ្នំខ្សាច់

*ពាក្យសាមញ្ញហៅថា «**ពូនភ្នំខ្សាច់**» ។ ការពូនភ្នំនេះគឺគេយកខ្សាច់សុទ្ធមកចាក់នៅកណ្តាលទីធ្លាដែលគេបានកំណត់ រួចពូនអោយចេញជារាងចេតិយបែរមុខទៅទិសខាងកើត ហើយគេសន្មត់ហៅថា «វាលុកចេតិយ» គឺតំណាងអោយព្រះចូឡាមណីចេតិយដែលសាងសំរាប់បញ្ចុះព្រះកេសា និងព្រះចង្កូមកែវនៃព្រះពុទ្ធបរមគ្រូ ។ ការពូនភ្នំនេះ បច្ចុប្បន្នតំបន់ខ្លះ គេនិយមពូនភ្នំអង្ករនៅសាលាធាន់ ឬ ក្នុងព្រះវិហារផងដែរ។ ភ្នំខ្សាច់ដែលគេពូនមិនមានកំណត់ថា ត្រូវមាន*

ខ្នាតតូចខ្ពស់ទាបប៉ុណ្ណាទេ គឺប្រព្រឹត្តទៅតាមការពេញចិត្តរបស់អ្នកស្អាង។ ប៉ុន្តែចាំបាច់ត្រូវមានភ្នំមួយនៅកណ្ដាល ហើយត្រូវមានភ្នំតូចៗ ៤ ព័ទ្ធជុំវិញគ្រប់ទិសតូចទាំង ៤ ។ នៅជុំវិញភ្នំគេមានធ្វើរាជវត័ តុបតែងលំអស្លឹកដូង ស្លឹករំសែជាបួនជ្រុងមានទ្វារ ចេញចូលតាមទិសធំទាំង ៤ ។ នៅជុំវិញរាជវតែគេមានរៀបរានទេវតាគ្រប់ទិសទាំង ៨។ នៅលើរានទេវតានិមួយៗគេរៀបស្លាធម៌មួយគូបាយសីមួយថ្នាក់ មួយគូ ទៀន៥ ធូប៥ ផ្កាភ្ញី និងអុជទៀនធូបថ្វាយ ។ នៅពីមុខភ្នំខ្សាច់ក្រៅរាជវត័ គេរៀបរានធំៗបីទៀត សំរាប់ថ្វាយព្រះយមរាជ ស្ថិតនៅកណ្ដាលខាងឆ្វេងរានព្រះយមរាជ គឺរានព្រះពុទ្ធគុណ និងខាងស្ដាំគឺរានព្រះពិស្ណុការ រានធំទាំងបីនេះគឺគេរៀបគ្រឿងសក្ការបូជាដូចរានទេវតាដែរ តែបាយសីខ្ពស់រហូតដល់៩ថ្នាក់ និងមានដាក់សំលៀកបំពាក់ឆ្វេងស្ដាំ ហើយមានដាក់ក្រយាថ្វាយសោយទៀតផង។ ការសាងវាលុកចេតិយនេះ ដោយគេសំគាល់ថានឹងបានជាផល្លានិសង្សវិសេសវិសាលណាស់ ដូចមានសំដែងក្នុងរឿង «អានិសង្សវាលុកចេតិយ» **មហាសំការសូត្រ** សំដែងថា ៖

-ពេលសង្ក្រាន្តឆ្នាំថ្មីជិតមកដល់ ព្រះបាទបសេនទិកោសលបានទូលសួរព្រះពុទ្ធថាក្រោយព្រះអង្គ បរិនិព្វានទៅបើដល់រដូចសង្ក្រាន្តចូលឆ្នាំថ្មីម្តងៗ តើខ្ញុំព្រះអង្គគួរបំពេញកុសលអ្វីខ្លះ? ព្រះពុទ្ធ ត្រាស់ថា « គួរសាងវាលុកចេតិយនៅឆ្នេរស្ទឹងទន្លេ ហើយនាំយកគ្រឿងសក្ការៈ ទៀនធូបគ្រឿងក្រអូប ផ្កា ជាដើមមកបូជាចុះ » ។ ព្រះអង្គបានបញ្ជាក់អំពីអានិសង្សនៃការសាងវាលុកចេតិយនោះ ថាមានអានិសង្សច្រើនវិសេសណាស់ ដូចគ្នានឹងស្រង់ទឹកព្រះសង្ឃដែរ។

-ក្រៅអំពីមហាសំការសូត្រនៅមានរឿងទៀតហៅថា «អានិសង្សវាលុកចេតិយ» ជារឿងដែលគេតែងជាភាសាខ្មែរមកយូរហើយ មានចំនួន១ខ្សែ សំដែងអំពីការសាងវាលុកចេតិយថាមានផល្លានិសង្សជាអនេកប្បការវេលាធ្វងវាលុកចេតិយគេច្រើនយករឿងនេះទេសន៍។ ក្នុងរឿងអានិសង្សវាលុកចេតិយនោះនាំនិទាន ៣ រឿងមកប្រកបជាឧទាហរណ៍គឺ :

- **និទានទី១** ដំណាលពីព្រះពោធិសត្វនាមបារិកជាអ្នកឈ្មួញសំពៅនាសម័យមួយ បារិកបើកសំពៅទៅជួញ បានប្រទះឃើញផ្នូកខ្សាច់សល្អនៅតាមឆ្នេរសមុទ្រក៏ បបួលពួកពាណិជដែលទៅជួញជាមួយគ្នា បើកសំពៅចៀងចូលចត

នៅទៀបផ្នូកខ្សាច់នោះហើយនាំគ្នាពូនជាវាលុកចេតិយឧទ្ទិសជាតំណាងចូឡាមណីចេតិយ ដែលបញ្ចុះព្រះចង្កូមកែវរបស់ព្រះពុទ្ធអំពីបុរាណ សឹងប្រតិស្ឋាននៅឋានត្រៃត្រិង្សទេវលោក ស្រេចហើយពួកពាណិជទាំងនោះក៏បេះយកផ្កាឈើមកបូជា ដើរប្រទក្សិណា៣ជុំហើយនាំគ្នាចុះសំពៅបើកចេញទៅជួញតទៅទៀត ។ បារិកពោធិសត្វ និង ពួកឈ្មួញអម្បាលនោះ លុះរំលាយខន្ធទៅ ហើយបានទៅកើតជាទេវបុត្រនៅឋានសួគ៌ជាច្រើនជាតិ លុះច្យុតពីសួគ៌ក៏កើតក្នុងមនុស្សលោកបានជាស្តេចឯករាជ្យជាច្រើនជាតិ និងត្រារាប់ពុំបានឡើយ ក្នុងទីបំផុត បារិកពោធិសត្វក៏បានត្រាស់ជាព្រះពុទ្ធ ដោយអំណាចផលានិសង្សដែលបានសាងវាលុកចេតិយ ។

- **និទានទី២** ដំណាលពីនាយនេសាទម្នាក់ (មិនប្រាកដឈ្មោះ) ថា៖ នាយនេសាទនោះធ្វើតែបាបសំលាប់សត្វបរិភោគតាំងពីតូចរហូតដល់ចាស់ មិនដែលបានធ្វើបុណ្យដល់ម្តងសោះ ។ នាថ្ងៃមួយមានភិក្ខុសង្ឃ១រូបនឹកអាណិតនាយនេសាទខ្លាំងណាស់ក៏គិតរកឧបាយអោយបានសាងបុណ្យកុសលខ្លះ លុះគិតដូច្នេះហើយ លោកក៏ឃ្លុំចីវរកាន់យកនូវបាត្រ និមន្តទៅរង់ចាំផ្លូវនាយនេសាទ ថ្ងៃនោះវេលាព្រឹកនាយនេសាទលីលំពែងមួយនិងពុនបាយ មួយកញ្ចប់ចេញទៅព្រៃដើម្បីស្វែងរកសត្វមកចិញ្ចឹមជីវិតដូចកាលសព្វដង។ ដំបូងនាយនេសាទប្រកែកដាច់ខាតថាមិនព្រមប្រគេន តែភិក្ខុនោះចេះតែទទូចសុំ អត់មិនបានក៏រំលែកបាយមួយពំនូតប្រគេន ។ ក្រោយមក កាលនាយនេសាទរំលាយខន្ធស្លាប់ទៅ ត្រូវពួកយមបាលឬយមកូបាលយកទៅសួរចម្លើយអំពីរឿងកាលនៅមនុស្សលោកនោះបានធ្វើបុណ្យខ្លះដែរឬទេ? នាយនេសាទតបថា មិនបានធ្វើបុណ្យអ្វីធ្វើតែបាបតាំងពីតូចមក។ ពួកយមបាលក៏នាំគ្នាចាប់បោះទៅក្នុងរណ្តៅភ្លើងនរកតែមិនឆេះត្រឡប់ជាខ្លាតចេញមកវិញយមបាលនឹកឆ្ងល់ក៏សួរបញ្ជាក់ថែមទៀត ទទួលនាយនេសាទក្រឡេកទៅឃើញអណ្តាតភ្លើងមានសម្បុរដូចចីវរលោកសង្ឃក៏នឹកឃើញដល់ទានដែលខ្លួនបានធ្វើ ទើបឆ្លើយថាកាលនៅ

មនុស្សលោកបានធ្វើទានបាយមួយពំនូតដល់ភិក្ខុ១រូបដែរ ។ ពួកយមបាលប្រាប់ថា បើដូច្នេះអ្នកឯងត្រូវទៅកើតឯឋានសួគ៌មួយអាទិត្យ លុះដល់ថ្ងៃទី៨យើងនឹងយកខ្លួនមកអោយទទួលទោសនៅឋាននរកនេះវិញ។ រំពេចនោះវិញ្ញាណរបស់នាយនេសាទក៏បានទៅកើតឯឋានសួគ៌ឈ្មោះថា **អន្ទំលោកង្សិនីទេវបុត្រ** មានទំហំ១២យោជន៍បរិបូរណ៍ទៅដោយសម្បត្តិ និងស្រីទេពកញ្ញាបំរើត្រៀបត្រាមាននាងសុវណ្ណឱរ៉ែជាទេពី។ អន្ទំលោកង្សិនីទេវបុត្រសោយសម្បត្តិមកបាន៦ថ្ងៃ នឹកឃើញដល់បណ្តាំយមបាល ក៏កើតសេចក្តីទុក្ខទោមនស្សពន់ប្រមាណហើយចូលទៅដេក នាងសុវណ្ណឱរ៉ែឃើញដូច្នេះ ក៏ចូលទៅសួរ អន្ទំលោកង្សិនីទេវបុត្រក៏រ៉ាយរឿងប្រាប់តាំងអំពីដើមរហូតដល់ចប់។ នាងសុវណ្ណឱរ៉ែក៏ឲ្យស្វាមីខ្លួនសាងវាលុកចេតិយ ហើយធ្វូងឲ្យស្រេចក្នុងថ្ងៃទី៧

អន្ទំលោកង្សិនីទេវបុត្រទើបចាត់ការសាងវាលុកចេតិយនិងធ្វើបុណ្យឆ្លងហើយស្រេចក្នុងរវាង ៧ ថ្ងៃនោះឯង ។ លុះដល់ថ្ងៃទី៨វេលាព្រឹកព្រហាម ពួកយមបាលក៏ទៅដល់ស្រែកហៅរកអន្ទំលោកង្សិនីទេវបុត្រអោយចេញមក គ្រានោះអន្ទំលោកង្សិនីទេវបុត្រគេចមុខចេញ នាងសុវណ្ណឱរ៉ែចេញមកទទួល។និយាយជាសំនួរតបយមបាលថា យើងមិនព្រមបើកអោយស្វាមីយើងទៅទេព្រោះស្វាមីយើងបានសាងវាលុកចេតិយនិងធ្វើបុណ្យឆ្លងរួចហើយ។ តែបើនៅតែត្រូវការយកខ្លួនទៅធ្វើទោសក៏ចូររាប់ខ្សាច់១ពែងនេះបើរាប់អស់ទើបយកទៅបាន។ យមបាលតបថាមិនសល់ក្រអ្វីទេការរាប់ខ្សាច់១ពែងប៉ុណ្ណោះ ហើយនាំគ្នារាប់តាំងពីព្រឹករហូតដល់ថ្ងៃត្រង់ គ្រាប់ខ្សាច់ដែលយកចេញអំពីពែងរាប់ដាក់ទៅខាងក្រៅ ទៅជាគំនរយ៉ាងធំកំពស់ស្មើចុងត្នោត តែឯគ្រាប់ខ្សាច់ក្នុងពែងគង់នៅដដែលគ្មានស្រកស្រុតទៅណាសោះ ពួកយមបាលទាល់ចំណេះនឹងរាប់ ហើយក៏នាំគ្នាត្រលប់ទៅយមលោកវិញ។ ចំណែកអន្ទំលោកង្សិនីទេវបុត្របាននៅសោយសម្បត្តិក្នុងទេវលោកអស់កាលអង្វែងតមកទៀត មិនបានទៅសោយទុក្ខក្នុងនរក ដូចដែលយមបាលកំនត់ទុកនោះទេ ។ ទាំងនេះក៏ដោយអំណាចផល្លានិសង្សដែលបានសាងវាលុកចេតិយ និងធ្វើបុណ្យឆ្លងដូចពោលហើយ។

- ***និទានទី៣*** *ដំណាលកាលពីរឿងចៅកំដិលខ្សាច់ ថាមានក្មេងម្នាក់ចេះតែទៅកក្ដិខ្សាច់នោះរាល់ៗថ្ងៃ ប្រឡាក់ទៅដោយដីខ្សាច់ព្រលូសតែរាល់ថ្ងៃ ទាល់តែគេហៅថា «ចៅកំដិលខ្សាច់»។ នាថ្ងៃមួយ ព្រះឥន្ទ្របើកទិព្វចក្ខុមើលឃើញចៅកំដិលខ្សាច់ពូនក្ដិដូច្នោះ ក៏ចាត់អោយនាងទេពធីតា១អង្គ ចុះមកធ្វើជាប្រពន្ធចៅកំដិលខ្សាច់។ ដំបូងចៅកំដិលខ្សាច់ប្រកែកមិនព្រមយកដោយថ្លៃងថា ខ្លួននៅក្មេងណាស់មិនទាន់ចេះរកស៊ីចិញ្ចឹម នាងទេពធីតាទើបទៅរកម្ដាយអាពុកចៅកំដិលខ្សាច់ថ្លៃងប្រាប់ថាខ្លួនជាទេពធីតាព្រះឥន្ទ្រប្រើ អោយចុះមកធ្វើជាប្រពន្ធចៅកំដិលខ្សាច់។ មាតាបិតាឃើញនាងទេពធីតាក៏ពេញចិត្តដោយនាងមានរូបឆោមល្អ ទើបសំណេះសំណាលលួងលោមចៅកំដិលខ្សាច់ទាល់តែព្រមយក ។ ចៅកំដិលខ្សាច់តាំងពីបាននាងទេពធីតាជាប្រពន្ធហើយ ខ្លួនប្រាណក៏ស្អាតបាតផូរផង់ល្អជាងពីមុនមកឆ្ងាយណាស់ដោយនាងទេពធីតា ជួយថែសំអាតទាំងសមរម្យគ្នានឹងប្រពន្ធនោះណាស់ ទាល់តែល្បីកេរ្ដិ៍ឈ្មោះទៅថា ចៅកំដិលខ្សាច់បាននាងទេពធីតាជាភរិយាល្អសមគ្នាណាស់ ។ គ្រានោះពួកមន្ត្រីសេនាបតីជាដើម ក៏បានទៅពិនិត្យមើល ឃើញដូចពាក្យគេដំណាល ។ ទទួលវេលានោះស្ដេចម្ចាស់ផែនដីសោយទីវង្គត គ្មានអ្នកទទួលរាជសម្បត្តិគ្រប់គ្រងផែនដី គេគិតឃើញថាចៅកំដិលខ្សាច់សមគួរជាព្រះរាជាម្ចាស់ផែនដី ក្រោយនោះគេក៏ធ្វើការផ្សងបុស្បុករកអ្នកមានបុណ្យធ្វើជាម្ចាស់ផែនដី បុស្បុកក៏ទៅត្រូវលើចៅកំដិលខ្សាច់ គេទើបនាំគ្នាអញ្ជើញទៅអោយសោយរាជ្យព្រមទាំងនាងទេពធីតា។ ផលដែលជាទិដ្ឋធម្មវេទនីយ ដូច្នេះលោកថាបាន ដោយហេតុដែលបានពូនក្ដិខ្សាច់នោះឯង។ កាលកើតមានរឿងសំដែងអំពីអានិសង្សនៃការស្អាងវាលុកចេតិយដូច្នេះហើយខ្មែរយើងបានដឹងរឿងទាំងនេះហើយក៏កើតសេចក្ដីជឿនិងជ្រះថ្លា ទើបបាននាំគ្នាស្អាងវាលុកចេតិយជាប់ជាប្រវេណី ដរាបមកដល់បច្ចុប្បន្នកាល។*

# បំបួសវាលុកចេតិយ

*ខ្សាច់ឬអង្ករ ដែលពុទ្ធបរិស័ទជញ្ជូនយកមកចាក់គរជាពំនូកខ្ពស់ដូចជាភ្នំនោះ មិនទាន់ឲ្យឈ្មោះថាវលុកចេតិយទេ លុះត្រាតែបំបួសនិងអធិដ្ឋានទៅជាភ្នំខ្សាច់ឬជាវាលុកចេតិយជាមុនសិនទើបពេញសិទ្ធិជាភ្នំខ្សាច់ឬវាលុកចេតិយ ។ ការបំបួសភ្នំខ្សាច់មានដូចខាងក្រោមនេះ៖*

*លោកអាចារ្យសូត្រធម៌អធិដ្ឋានវាលុកចេតិយអោយតំណាងព្រះចូឡាមណីចេតិយដោយឲ្យពុទ្ធបរិស័ទនាំគ្នាថាតាមៈ* ***ឱកាស មយំ ភន្តេ ឥមំ វាលុកចេតិយំ គិរីបព្វជំ បរិមណ្ឌលំ មកាសិត ឧទ្ទិស្ស ចូឡាមណីចេតិយំ មង្គលំ អធិដ្ឋាមិ*** (ម)។ ***ទុតិយម្បិ...តតិយម្បិ...*** ។ *រួចយកកំណាត់សប្រវែងប្រមាណមួយម៉ែត្រកន្ទះទៅពានាពាក់ឆៀង ព្រះចេតិយដែលតាមសម្ដីអ្នកស្រុកហៅថា* ***«បំបួសភ្នំ»*** *។ ក្នុងឱកាសនោះដែរព្រះសង្ឃសូត្រធម៌ ចំរើនព្រះបរិត្តនៅសាលាធម្មដោយបន្តអំបោះមកដល់ភ្នំទាំងអស់។ ភ្នំដែលបានឡើងជាអង្គចេតិយហើយអ្នកណាមួយទៅជាន់រំលងឬរំលាយមុនគេផ្សឹកទុកជាត្រូវទទួលបាប ។*

# ផ្សឹកវាលុកចេតិយ

*ក្រោយពីការធ្វើកិច្ចសព្វគ្រប់ហើយ លោកអាចារ្យសូត្របួងសួង និងថ្វាយគ្រឿងសក្ការៈដល់អស់ទេវតា ព្រះយមរាជ ដែលតែងតែត្រួតត្រាមើលការខុសត្រូវដល់មនុស្សលោក ដើម្បីសុំខមាទោសចំពោះអំពើខុសឆ្គងទាំងឡាយកន្លងមក ដោយការអនុគ្រោះ សុំអោយផ្ដាច់កម្មផ្ដាច់ពៀរ និងសុំសេចក្ដីសុខចំរើនតរៀងទៅ ។ បន្ទាប់លោកអាចារ្យបានឧទ្ទិសកុសលជូនដល់អ្នកដែលចែកឋានទៅមានមាតាបិតាជីដូនជីតាព្រមទាំងញាតិមិត្តទាំងអស់ផង។ ថ្ងៃបន្ទាប់មកទៀតពុទ្ធបរិស័ទមកជួបជុំគ្នាលោកអាចារ្យចាប់ដំណើរការថ្វាយបង្គំព្រះសមាទានសីលនៅធម្មសាលា ។ បន្ទាប់មកគេនាំគ្នារាប់បាត្របន្តហូរហែ ទាល់តែអស់អ្នកដែលមានសទ្ធា។ នៅពេលបញ្ចប់ការរាប់បាត្រគេបានកាន់ទៀន ធូប ផ្កាគ្រប់ ដៃទៅកាន់ភ្នំខ្សាច់។ អាចារ្យចាប់ផ្ដើមពិធីនៅចំពោះ*

*ភ្នំខ្សាច់ដូចកាលពីល្ងាចម្តងទៀត ។ ជាមួយគ្នានេះដែរព្រះសង្ឃសូត្រពុទ្ធមន្តប្រសិទ្ធិពរជ័យ សិរីមង្គលនៅធម្មសាលា។ អាចារ្យបានបន្តពិធីនៅខាងក្រោមុខភ្នំគឺច្ចង់បុណ្យ ហើយធ្វើកិច្ចផ្សឹក ភ្នំវិញដោយពោលថា : «**ឥមំវាលុក ចេតិយំ បច្ចក្ខាមិ**» ប្រែថា : «ខ្ញុំផ្សឹកឥឡូវនេះនូវវាលុកចេតិយ នេះចេញ» គឺលែងប្រកាន់ថាជាចេតិយទៀតហើយអ្នកណារំលាយក៏គ្មានបាបដែរ ។ គេនាំគ្នា ចូលធម្មសាលាដើម្បីវេរភត្តប្រគេនព្រះសង្ឃឆាន់ត្រង់ ។ ពេលរសៀលគេជួបជុំគ្នាដើម្បីន មស្សការថ្វាយបង្គំព្រះនិងអារាធនា ព្រះសង្ឃសំដែងធម្មទេសនា។ កម្មវិធីជាបន្តគេនាំគ្នាសំអាត ព្រះពុទ្ធរូប ហើយបាចផ្កាបាញ់ទឹកអប់ «**ស្រង់ព្រះ**» ជាកិច្ចបញ្ចប់ពិធីបុណ្យចូលឆ្នាំថ្មី។ នេះជាពិធីតាមបែបសាសនា ៕*

# រួបរួមអានិសង្ស

*ព្រះបរមសាស្តាទ្រង់បានសំដែងអំពីអានិសង្សដែលបានកសាងបុណ្យកុសលក្នុងឱកាសដាច់ឆ្នាំ ចាស់ចូលឆ្នាំថ្មីដោយពិស្តារថា៖ «អ្នកដែលបានផ្ងូតទឹកអោយមាតាបិតាគ្រូឧបជ្ឈាយ៍ អាចារ្យ ឬព្រះសង្ឃ និងបានសាងវាលុកចេតិយក្នុងឱកាសសង្ក្រាន្តនោះ រមែងបានអានិសង្សដូចគ្នា គឺបានជាស្តេចម្ចាស់ផែនដីមានរិទ្ធិដ៏មហិមាសំបូរដោយរតនៈ៧ប្រការ ដេរដាសដោយពពួកនាង នារីសឹងមានរូបឆោមដ៏ល្អនិងសំបូរដោយចតុរង្គសេនា ជាអ្នកបាននូវសេចក្តីសុខគ្រប់យ៉ាង» ។ អ្នកដែលបានលែងសត្វតិរច្ឆាន ដូចយ៉ាងមាន់ ទន្សោង បក្សី ត្រី អណ្តើក...ជាដើម ដោយ អំណាចដែលបានលែងសត្វអម្បាលនោះអ្នកនោះរមែងជា អ្នកមានអាយុយឺនយូរជាអ្នកមាន សុខច្រើនឥតមានរោគភ័យមកបៀតបៀនក្នុងកាលទាំងពួង ប្រកបតែសេចក្តីសុខ។ ដោយផល្លា និសង្សដែលបានស្រង់ព្រះសង្ឃនិងពូនភ្នំខ្សាច់ អ្នកនោះទោះទៅកើតក្នុង ភពណាៗក្តីរមែង មានរូបឆោមល្អជាទីជ្រះថ្លាដល់អ្នកបានឃើញ ជាអ្នកមានសម្បុរកាយផូរផង់ ជាទីគាប់ចិត្ត ជាទីគួរអោយមើល ជាអ្នកមានប្រាជ្ញាស្រួច ជាអ្នកក្លាហាន ជាអ្នកទ្រទ្រង់នូវព្រះ សូត្រនិង ព្រះវិន័យ ជាអ្នកទ្រទ្រង់និងចេះចប់នូវព្រះបិដក ជាអ្នកមានអាយុយឺនយូររាល់ៗជាតិ ជាអ្នក មានបុត្រភរិយានូវគណា ញាតិសុទ្ធតែជាអ្នកឧត្តមថ្លៃថ្លា។ ទាំងនេះជាអានិសង្សផ្ងូតទឹកនិងសាង វាលុកចេតិយក្នុងពេលចូលឆ្នាំ។ ជាពិសេសទៅទៀតពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លា និង*

ប្រកបទៅដោយកតញ្ញូកតវេទិតាធម៌ បានថ្វាយទេយ្យវត្ថុជាទានដល់ព្រះសង្ឃដើម្បីឧទ្ទិសមគ្គផលកុសលដល់បុព្វការីជន និងញាតិទាំង៧សន្តាន និងបានបូជានូវទេយ្យទានទាំងឡាយ មានបាយទឹក នំចំណី សំពត់អាវសារស្បៃ និងគ្រឿងប្រើប្រាស់ផ្សេងៗដល់ មាតាបិតា ជីដូនជីតា និងចាស់ព្រឹទ្ធាចារ្យ នៅក្នុងពេលចូលឆ្នាំនេះ រមែងមានអានិសង្សគ្រារាប់ពុំបាន នឹងបានជួបតែនឹងពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្បត្តិទាំងឡាយបីប្រការគឺ សម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វានក្នុងជាតិណាមួយមិនខានឡើយ ។ ដោយប្រការដូច្នេះហើយ សូមខេមរបុត្រទាំងឡាយកុំគប្បីធ្វេសប្រហែសបណ្តោយអោយបុញ្ញកាលដ៏ឧត្តមនេះកន្លងផុតទៅដោយពុំបានធ្វើអ្វីឲ្យសោះ ។ ពិតមែន ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទ្រង់បានសំដែងថា« ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះឈ្មោះថាជានក្ខត្តប្ញក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ ទានដែលបុគ្គលបានបូជាហើយ ដល់ព្រហ្មចារីបុគ្គលទាំងឡាយក្នុងពេលនោះឈ្មោះថាជាគ្រឿងបូជាល្អ, ក្នុងថ្ងៃនោះ កាយកម្មក៏ឈ្មោះថានាំអោយមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន មនោកម្មក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន, បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួដល់សេចក្តីចំរើនយ៉ាងនេះហើយ រមែងបាននូវប្រយោជន៏ដ៏ចម្រើនទាំងឡាយៗ ព្រះពុទ្ធោវាទនេះទ្រង់បញ្ជាក់ថា ក្នុងពេលណា វេលាណា ថ្ងៃណាក៏ដោយ ឲ្យតែបុគ្គលប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត និងធ្វើទានសីលកុសលផលបុណ្យនានា ពេលនោះ វេលានោះ ថ្ងៃនោះ គឺជាថ្ងៃ ដែលល្អ ដែលជាមង្គល ដែលនាំឲ្យមានសេចក្តីចំរើនទាំងអស់ ដោយមិនចាំបាច់មើលឫក្សពារពេលានោះទេ ។ សរុបសេចក្តីមកបានន័យថាសព្វសត្តនិករទាំងឡាយអាចធ្វើបុណ្យសុន្ទរ៍ទានបានគ្រប់ពេល ហើយសេចក្តីចំរើននិងសុភមង្គលទាំងឡាយកើតមានគ្រប់ខណៈដែលសត្តនិករទាំងនោះបានសាងនូវបុណ្យកុសល។

គ្រាន់តែថា សំអាងទៅលើការមមាញឹកចំពោះជីវភាពប្រចាំថ្ងៃរបស់ពុទ្ធបរិស័ទ រហូតដល់មានមានបងប្អូនខ្មែរខ្វះគ្មានឱកាសដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំទៀតផង សូម្បីតែមួយឆ្នាំមានម្តងក៏មិនអាចឆ្លៀតឱកាសបាន ។ ហេតុនេះគួរណាស់តែមានការលះបង់ខ្វះៗ ចែករំលែកពេលវេលាដ៏មានតម្លៃនោះ យ៉ាងហោចណាស់ក៏មួយឆ្នាំម្តង ដើម្បីប្រយោជន៍អនាគតរបស់ខ្លួនផង ។ ម្យ៉ាងទៀត បុណ្យចូលឆ្នាំខ្មែរគឺជាបុណ្យប្រពៃណីប្រចាំជាតិខ្មែរ ហើយថ្ងៃបុណ្យចូលឆ្នាំខ្មែរគឺជា

*ថ្ងៃជួបជុំនៃមហាគ្រួសារខ្មែរទូទាំងពិភពលោក កំណត់ដើម្បីធ្វើបុណ្យកុសលរួមគ្នា និងសាមគ្គីគ្នាជាធ្លុងមួយថែរក្សាទំនៀមទំលាប់ប្រពៃណីដ៏មានតម្លៃរបស់បុព្វបុរសយើង ជាឱកាសសប្បាយរីករាយក្នុងបុណ្យកុសល ជួបជុំក្រុមគ្រួសារគណាញាតិ និងមិត្តជិតឆ្ងាយ បង្កើតភាពស្និទ្ធស្នាលដល់គ្នានិងគ្នា ស្រលាញ់ស្មោះសរល្អរកគ្នា ក្នុងនាមជាខេមរបុត្រដែលមានតំណក់ឈាមជាខ្មែរ អ្នកមានវប្បធម៌ប្រពៃណីរបស់ខ្លួនផ្ទាល់ និងមានតំលៃខ្ពង់ខ្ពស់ឧត្តុងឧត្តម ។ ហេតុនេះហើយទើបយើងមិនគួរបណ្តោយឲ្យឱកាសដ៏ល្អនិងមានន័យសំរាប់ជីវិតនេះកន្លងផុតទៅទទេៗឡើយ។*

*សូមទេវតាឆ្នាំថ្មីជួយថែរក្សាខេមរជនទាំងអស់អោយបានជួប្រទះតែនឹងសេចក្តីសុខចម្រុងចម្រើន*
*សិរីសួស្តីវិបុលសុខគ្រប់ប្រការ ឈ្នះមារសត្រូវគ្រប់ទិសទី!*

**ព្រះធម៌រមែងរក្សាអ្នកប្រតិបត្តិធម៌, ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ**

**បើអ្នកចង់អោយទេវតាជួយ សូមកុំភ្លេចជួយខ្លួនឯងជាមុនសិន ទេវតានឹងជួយអ្នកជាមិនខាន!**

---

*ចងក្រងដោយ ភិក្ខុវណ្ណគុត្តោ ស្វាត សាលឿម*

<u>ឯកសារយោង:</u>

- គេហទំព័រ វីគីភីឌាភាសាខ្មែរ http://km.wikipedia.org/wiki
- ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំទី ៤៨ លេខ១ ព.ស ២៥៣៧, គ.ស ១៩៩៤
- សត្តបរិត្ត ទ្វាទសបរិត្ត ព.ស ២៥១៥
- លំអានទំនៀមខ្មែរបុរាណ ព.ស ២៥៤៨


វត្តពោធិការាម នៃ ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា
1197 Deer Park Road, Ottawa, Ontario, Canada, K2E 6H5
www.bodhikaram.com